

# កណ្ដុរក្នុងផ្ទះ

Let's Read
The Asia Foundation



នៅក្នុងផ្ទះ មានកណ្ដុរមួយក្បាល។ លោកយាយឃើញវា មុនគេ។ គាត់ស្រែកថា ”កណ្ដុរ!” រួចគាត់ក៏លោតឡើងលើ សាឡុង។ ខ្ទើយកល់ ក៏ធ្លាក់រាយពេញលើកម្រាលឥដ្ឋ។



ពុកស្រែកសួរថា "នៅឯណា?" រួចគាត់ក៏ឡើងទៅលើបង្អួច។ គាត់ទាញវាំងននធ្លាក់ចុះក្រោម។ ម៉ែក៏លាន់ថា"នៅទីនោះ!" ពោលរួច គាត់ក៏ហក់ឡើងទៅលើតុ ធ្វើធ្លាក់បែកចានអស់។



”ចាប់វាឲ្យបាន!” មិថុនា ក៏ស្រែកប្រាប់ទៅឆ្មា។ ប៉ុន្តែឆ្មា គ្រាន់តែឃើញកណ្តុរ ក៏រត់គេចទៅពួននៅក្រោមគ្រែបាត់! មិថុនា រត់តាមក្រោយឆ្មា ហើយស្រែកថា ”កណ្តុរ!”



ម៉ែនិយាយដោយក្លាហានថា ”ទុកឲ្យខ្ញុំដេញវាចេញ!” ថារួចម៉ែក៏យកអំបោសមករុកចុះឡើង។ ពុកក៏លាន់មាត់ ”កណ្ដុរ! វានៅក្រោយម៉ែវាឯងហ្នឹង!” ម៉ែឃើញកណ្ដុរ ក៏រត់ទៅពួននៅក្រោមគ្រែ។



លោកយាយ លោតចុះពីសាឡុងហើយស្រែកថា ”យាយដឹងថាត្រូវធ្វើម៉េចហើយ!” គាត់មូរក្រដាសកាសែត ហើយរុកចុះឡើង។



ពុកពោលតិចៗថា ”អូ វីររហើយ!” គាត់មិនអាចតោងឡើងទៅលើទៀតបានទេ។ គាត់ខំស្រវាចុះពីបង្អួចវិញយ៉ាងប្រុងប្រយ័ត្ន ទៅពួននៅក្រោមគ្រែដែរ ដើម្បីកុំឲ្យកណ្ដុររកគាត់ឃើញ។



អ្នកទាំងអស់ក៏ស្រែកព្រមគ្នាថា "កណ្ដុរនៅក្នុងផ្ទះ!" សំឡេងនេះ ធ្វើឲ្យកូនង៉ែតភ្ញាក់ឡើង។ នាងក្រោកអង្គុយលើកម្រាល ហើយយកដៃញីភ្នែកទាំងមមើ។ តើអ្វីនៅលើខ្នើយរបស់នាង?



វាមានភ្នែកពីរ ជើងបួន ហើយកន្ទុយមួយយ៉ាងវែង។ ក្មេងតូច និយាយថា "កណ្ដុរ!" រួចទះដៃយ៉ាងរីករាយ។ ក្មេងតូចនោះ មើលទៅកណ្ដុរ។ កណ្ដុរក៏រត់គេច ដោយក្មេងតូចដេញតាមវា ពីក្រោយ!



កណ្ដុរ ហក់ឡើងលើសាឡុង ឡើងលើបង្អួច លោតឡើងលើតុ
ដួលដាំដូងលើខ្នើយ...



...វារត់តាមចន្លោះរាំងនន កាត់ពីលើចាន ហើយក៏ចេញប្រូច
តាមទ្វារទៅបាត់!

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Mouse in the House*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/
Contributing translators: Chou Chinith